# រឿង មហាចោរនៅទល់ដែន

**ភាគទី៦០** (ស្រីទុគ៌ត)

បាទសិស្សខ្ញុំៗ បានបង្ហាត់វិជ្ជាគ្រប់យ៉ាង ទាំងអក្សរទាំងក្បាច់ចម្បាំងជាមួយគីរីសុមេរុ?

អ្នកណា គីរីសុមេរុ?

ជាក្មេខ្ញុំ នាងមិនស្គាល់ទេៗ គាត់នោះចាស់ណាស់ហើយ តែជាមនុស្សកំពូលមនុស្សៗ

ចាំះ! លោកពូធ្លាប់ឃើញប្ដីខ្ញុំមែនឬទេ?

ខ្ញុំមិនដែលជួបទេ តែខ្ញុំមានគ្នីគ្នាទៅរកពល់ពេលៗ

លោក! ប្ដីខ្ញុំសុខសប្បាយជាទេ?

សុខសប្បាយជាទេ

គាត់ជាត់ ឬស្គម?

នៅដដែលដូចមុនទេមើលទៅៗ ខ្ញុំមិនសូវដឹង ព្រោះយើងឃ្លាតគ្នាតាំងតែពីពេលនាងចេញពីសិរីសោភ័ណមកនោះផងៗ

អូ! យូរណាស់ហើយ តែលោកពូ! លោកពូ! ឱទុក្ខខ្ញុំធំណាស់ៗ ប្ដីខ្ញុំនឹងស្មានថា ខ្ញុំនេះជាស្រីដែលក្បត់គាត់ៗ

ខ្ញុំជាសាក្សីស្រាប់ តើភ័យអ្វី?

ចាំះ! ចាំះ! សូមលោកពូមេត្តាជួយពន្យល់គាត់ផងៗ ឱ! ទុក្ខខ្ញុំមានយូរហើយ ពេលនេះខ្ញុំទើបបានសប្បាយម្ដងៗ

ចូលនាងកុំព្រួយឲ្យសោះ

ហ៊ឹ! លោកពូមានគុណនឹងខ្ញុំដល់ម្ល៉េះ តើលោកពូនាមឈ្មោះអី? នៅស្រុកណា? ប្រពន្ធឈ្មោះអី? មានកូនប៉ុន្មាន?

ខ្ញុំជាមនុស្សអត់ឈ្មោះ អត់ស្រុកទេស អត់គ្រួសារ អត់កូនចៅទេ

ម៉េចក៏យ៉ាងដូច្នោះ?

អត្ថបទដោយ៖ មាស សុភាព

សូមនាងកុំចង់ដឹងរឿងខ្ញុំឲ្យសោះ។

មនុស្សធ្វើមុខស្រងូតស្រងាត់ក្រៃពេក ដែលនាំឲ្យនាងទេវីមានចិត្តអាណិតរកអ្វីមកប្រដូចពុំបាន។

ឃើញដូច្នោះ នាងក៏អត់ដង្ហើម មិនសួរអ្វីពីរឿងនេះទៀតឡើយ។

ឪ លោកពូ! មីងចន្ទនៅឯណា?

នៅបន្ទប់ខាងមុខ

ខ្ញុំសុំអោយគាត់មកនៅជាមួយខ្ញុំបានទេ?

ហាស១ ខ្ញុំមិនចង់ដូច្នោះទេ

ម៉េចក៏ដូច្នោះ?

ព្រោះស្រី១ បើនៅជិតគ្នា ចេះតែនាំគ្នានិយាយពីទុក្ខ រួចយំនាំឲ្យខ្ញុំវេទនាចិត្តណាស់។

មិនអីទេ ខ្ញុំអផ្សុកណាស់ ខ្ញុំសុំឲ្យគាត់មកនៅជាមួយខ្ញុំមក។ រួចកូនខ្ញុំផង។

បាទ! កុំនិយាយគ្នា រួចកុំយំណ៎ា!

ចា៎ះ! ខ្ញុំជានាជូនលោកពូ។

លំដាប់ក្រោយពីនោះ មីងចន្ទ និងនាងបទុមក៏បានមកនៅជាមួយនាងទេវី។ រីឯបុរសមិនស្គាល់ឈ្មោះក៏ឡើងទៅលើដំបូលទូកវិញ អ្នកចែវទាំងអស់មានបួននាក់ អ្នកកាច់ចង្កូតម្នាក់ទៀតត្រូវជាប្រាំនាក់។ បុរសឃើងបញ្ជាឲ្យក្មេងម្នាក់ដាំបាយ បម្រើទឹកក្តៅ ទឹកត្រជាក់ដល់ស្រីទុគ៌តទាំងពីរប្រាណ។ ក្នុងវេលាថ្ងៃនេះ បុរសនិទ្រាលក់យ៉ាងស្កប់ស្កល់លើដំបូលទូក ដែលលឿនស្ទុងស្ទេវបណ្តោយតាមទឹកហូរ។

(**ក្បួនការពារឯករាជ្យ**)

ចលនាតស៊ូដោះលែងជាតិដែលមានមានទ្ធដឹកនាំនោះ ក៏ចេះតែធំឡើង១ជាលំដាប់។ បើតាមសង្កេតការលូតលាស់ល្អនេះ មកពីហេតុដម្រៅបីយ៉ាង:

១ មកពីការងារធ្វើមានគោលបំណងច្បាស់លាស់ គឺបណ្តេញខ្មាំងជាតិយកឯករាជ្យមាតុភូមិ។

អត្ថបទដោយ៖ មាស សុភាព

២ មកពីមធ្យោបាយដើម្បីសម្រេចបំណងនេះ មានក្រឹត្យវិន័យម៉ឺងម៉ាត់ល្អជាក់ស្តែងៗ អ្នកណាខុសត្រូវតែទទួលទោសតាមខុស មិនថាអ្នកតូចឬអ្នកធំឡើយ។ ភ្នាក់ងារម្នាក់ៗដឹងមុខការនិងករណីកិច្ចរបស់ខ្លួនគ្រប់ផ្នែកគ្រប់ក្រុមៗ ក្រឹត្យវិន័យទាំងឡាយនោះគឺអាចចងជាក្បួនបដិវត្តមួយដ៏វិចិត្រសម្រាប់រៀនអោយស្គាល់នូវអស់បញ្ហាជាតិខ្មែរ ឲ្យយល់អស់នូវរឿងខ្មែរ ឲ្យជឿនូវអស់តម្លៃជាតិខ្មែររួចអោយហ៊ានធ្វើនូវអស់ការងារដែលបានគ្រោងទុកមកៗ ក្បួនបដិវត្តនេះជាប្រពៃណីសម្រាប់បំភ្លឺផ្លូវឲ្យជនអ្នកតស៊ូដើរតែលើគន្លងត្រូវជានិច្ចៗ មិនតែប៉ុណ្ណោះ ការតស៊ូបំភ្លឺហើយដោះស្រាយបញ្ហាទុក្ខរបស់រាស្ត្រ ព្រមទាំងបញ្ហាច្បាប់សម្រាប់ពលរដ្ឋ និងច្បាប់របស់សង្គម ដែលមានអធិបតេយ្យភាពបរិបូណ៌ពិតៗ មានបញ្ហាសេដ្ឋកិច្ច វប្បធម៌ សិល្បៈ អក្សរសាស្ត្រ យុត្តិធម្មសាស្ត្រជាដើមៗ

៣ មកមេផ្តើម អ្នកដឹកនាំ និងសមាជិកតស៊ូ គឺសុទ្ធសឹងពិតៗ ជាអ្នកស្នេហាជាតិ ដែលធ្លាប់មានការពិសោធន៍ធំៗក្នុងរឿងជាតិ មានសតិសម្បជញ្ញៈយ៉ាងមោះមុតក្នុងកិច្ចប្រតិបត្តិការពុំបណ្តោយខ្លួនឲ្យធ្លាក់ក្នុងកំហុសដែលរំលោភលើជាតិនោះៗ

ហេតុនេះអង្គការតស៊ូរបស់ប្រជាជាតិ ដឹកនាំដោយប្រជារាស្ត្រដើម្បីប្រជារាស្ត្រអង្គការដែលរស់មានជីវិតដូចដើមឈើដែលចេះតែធំឡើងៗ រឹងឡើងៗ ខ្ពស់ឡើងៗជានិច្ចៗ គឺជាអង្គការដែលមានអនាគតយ៉ាងពិស្តារៗ

ចំណែកខាងនាទីគ្រប់គ្រងសៀម ដែលមានកាមា និងព្រះនាងមណីជាបរិវារ ព្រឹត្តិការណ៍មានផ្ទុយទៅវិញៗ រាល់ថ្ងៃ មានតែមនុស្សអាក់អន់ចិត្តដែលមានចំនួនកាន់តែច្រើនៗ សង្គមគ្មានរបៀបរៀបរយនាំឲ្យមនុស្សរួដណ្តើមយកសុខផ្ទាល់ខ្លួន ម្ល៉ោះហើយមនុស្សទាំងអស់ច្រើនតែ ដោរដោតទៅដោយលោភា ទោសោ មោហោ គ្រប់គ្នាៗ រឿងនេះជាហេតុធ្វើឲ្យ មានការជិះជាន់គ្នា មានការជញ្ជក់ឈាមគ្នាគ្មានអៀនខ្មាស់ មានការប្រើអំណាចហួសហេតុ ដើម្បីប្រយោជន៍បុគ្គល មានការឃ្លានីសព្យាបាទគញនដោយអយុត្តិធម៌ៗលៗ ប្រយោជន៍សាធារណៈគឺជាប្រយោជន៍ ប្រជារាស្ត្រដែលជាភាគច្រើនក៏ត្រូវឥតបាន គិតគូរដល់ឡើយៗ

ជូន់ទៅទៀត កាលណោះនគរលែងប្រើច្បាប់ មនុស្សជ្រើម មន្ត្រីខូច រាស្ត្រគ្មានសិទ្ធិសេរីភាពអ្នកស្រែរងទុក្ខវេទនា អ្នកក្ររឹតតែក្រ លែងងើបមុខរួចៗ គឺជាសង្គមពុករលួយៗ សង្គមបែបនេះរួញទៅៗ នាំឲ្យថយកម្លាំងជាដរាបរាល់ថ្ងៃៗ ពិសេស គឺសង្គមមួយដែលគ្មានអនាគតៗ សង្គមនេះដួលខ្លួនឯង មិនបាច់អ្នកណាច្រានរំលំឡើយៗ

**(សូមរង់ចាំតាមដានភាគទី៦១ នៅសប្តាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព